អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១៤/២៣ ចេញផ្សាយ ខែកុម្ភៈ ឆ្នាំ២០២៣

# ការគ្រប់គ្រងប្រតិបត្តិការ

## ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងប្រតិបត្តិការ

តាមការសិក្សាស្រាវជ្រាវពីទិដ្ឋភាពជាក់ស្តែង គ្រប់ស្ថាប័នទាំងអស់មិនថាជាស្ថាប័នសាធារណៈ ឬស្ថាប័នឯកជនទេដើម្បីអាចដំណើរការបានជោគជ័យរយៈពេលវែង ស្ថាប័ននោះត្រូវមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយដ៏រឹងមាំ ដែលក្នុងនោះការគ្រប់គ្រងប្រតិបត្តិការជាផ្នែកមួយដ៏សំខាន់ក្នុងការជួយស្ថាប័នលើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការទទួលខុសត្រូវលើសកម្មភាពការងារ ក្នុងន័យប្រាកដថា ស្ថាប័នពិតជាមានភាពសុចរិត ភាពរឹងមាំ និងទំនុកចិត្តពីភាគីជាប់ពាក់ព័ន្ធ។




## និយមន័យ

បើតាមការសិក្សាទៅលើ**ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** អត្ថន័យនៃពាក្យការគ្រប់គ្រងប្រតិបត្តិការ គឺ**ការគ្រប់គ្រង** ជាវិធីសាស្ត្រក្នុងការប្រើប្រាស់ធនធាន ឬការចាត់ចែងធនធានឱ្យអស់ពីលទ្ធភាព ដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ណាមួយរបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ **ប្រតិបត្តិការ** សំដៅដល់មុខងារប្រតិបត្តិការស្នូលរបស់ស្ថាប័នមួយដែលមុខងារប្រតិបត្តិការសំដៅដល់សកម្មភាពទាំងឡាយណាដែលផ្តោតលើមុខងារប្រតិបត្តិការរាប់បញ្ចូលដំណើរការក្នុងការបំលែងវត្ថុធាតុដើមទៅជាផលិតផលសម្រេច។ ក្នុងន័យទូទៅ ប្រតិបត្តិការសំដៅដល់ដំណើរការសកម្មភាពណាមួយដែលស្ថាប័នអនុវត្តដើម្បីសម្រេចបាននូវលទ្ធផលជាក់លាក់មួយ។

ជាអត្ថន័យរួម **ការគ្រប់គ្រងប្រតិបត្តិការ** សំដៅទៅលើការគ្រប់គ្រងការអនុវត្តរបស់ស្ថាប័ន ដើម្បីទទួលបាននូវកម្រិតប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពអតិបរមាទាក់ទងនឹងការប្រើប្រាស់ធនធាន។ ការគ្រប់គ្រងប្រតិបត្តិការ គឺពាក់ព័ន្ធនឹងសកម្មភាពការសម្រេចចិត្ត និងទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រងស្ថាប័ន។ ដើម្បីធានាថាផលិតផលឬសេវាដែលបានផ្តល់ជូនអតិថិជនមានគុណភាពខ្ពស់ និងមានអត្ថប្រយោជន៍ខ្ពស់។



## គោលបំណង

យោងតាមការសិក្សាស្រាវជ្រាវលើ**សៀវភៅណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ** គោលបំណងនៃការគ្រប់គ្រងប្រតិបត្តិការ គឺដើម្បីលើកកម្ពស់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ ព្រមទាំងរួមចំណែកផងដែរដល់ការផ្តល់គណនេយ្យភាព និងតម្លាភាព។

# អត្ថបទប្រចាំខែ

អង្គភាពសវនកម្មផ្ទៃក្នុង

លេខ ១៤/២៣ ចេញផ្សាយ ខែកុម្ភៈ ឆ្នាំ២០២៣




**១.ប្រសិទ្ធភាព** សំដៅដល់ការសម្រេចបាននូវគោលដៅ និងគោលបំណង ដោយប្រើធនធានដែលបានកំណត់ ព្រមទាំងទទួលបានលទ្ធផលដែលរំពឹងទុក (Outcome)។ គោលដៅ និងគោលបំណង (Output) ជាអ្វីដែលស្តែងឡើង អាចមើលឃើញ ដោយឡែកលទ្ធផលរំពឹងទុក (Outcome) អាចមើលមិនឃើញបាននោះទេ ដែលទាមទារឱ្យមានការវាស់វែង។

**២.ប្រសិទ្ធផល** សំដៅដល់ការសម្រេចបានទៅដល់គោលដៅអតិបរមាជាមួយនឹងធនធានដែលបានកំណត់ ឬក៏សម្រេចដល់គោលដៅដែលប្រើប្រាស់ធនធានតិចជាងធនធានដែលបានកំណត់។ ក្នុងន័យនេះ ប្រសិទ្ធផល ឬស័ក្តិសិទ្ធភាព មានន័យថា ការសម្រេចបានផលខ្ពស់ជាងមុនជាងការរំពឹងទុក ជាមួយនឹងធនធានដែលបានកំណត់ ម្យ៉ាងទៀត ធនធានដដែល (Input) បានផលខ្ពស់ជាងមុនជាមួយធនធានដែលបានកំណត់។

**៣.ភាពសន្សំសំចៃ** គឺជាការធ្វើអប្បបរមាថ្លៃដើមនៃធនធាន ដែលធនធានត្រូវបានប្រើប្រាស់គួរតែមានក្នុងកំឡុងពេលកំណត់មួយប្រកបដោយគុណភាព និងបរិមាណសមស្រប ព្រមទាំងមានតម្លៃល្អសមរម្យ។

## អត្ថប្រយោជន៍

ការគ្រប់គ្រងប្រតិបត្តិការមានផលប្រយោជន៍ដល់ស្ថាប័នក្នុងសម្រេចបានការគ្រប់គ្រង និងការអនុវត្តមួយប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលនៅក្នុងមុខងារ និងភារកិច្ចរួមមាន៖

- រក្សាសុវត្ថិភាពធនធានរបស់ស្ថាប័ន
- ធានាការទុកចិត្តទិន្នន័យ និងព័ត៌មាន
- លើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រតិបត្តិការ និងការគ្រប់គ្រង
- ធានាដល់ផែនការ កម្មវិធី និងគោលបំណងត្រូវបានអនុវត្តអនុលោមតាមគោលនយោបាយរបស់ស្ថាប័ន។



**អត្ថបទ៖ កញ្ញា អ៊ុន សៀកម៉ី**

**ឯកសារយោង៖**

*១-សេចក្តីណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ របស់អាជ្ញាធរសវនកម្មជាតិ*

*២-ឧត្តមានុវត្តន៍ស្តីពីការគ្រប់គ្រងប្រតិបត្តិការ របស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**។*